CITY OF LONG BEACH

# PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 10 ខែកុម្ភៈ ឆ្នាំ 2021

ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងឡុងប៊ិច, 562.570.NEWS, jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# សាលាក្រុងឡុងប៊ិច បានចេញ បទបញ្ជាឱ្យនៅផ្ទះមានសុវត្ថិភាពជាង ដែលបានធ្វើបច្ចុប្បន្នភាពរួច ដើម្បីអនុញ្ញាតឱ្យមាន សេវាសាសនា និងពិធីបុណ្យវប្បធម៌ មានមនុស្សចូលរួមនៅក្នុងអគារ ដោយមានការដាក់កំហិត ។

ឡុងប៊ិច, CA - នាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស នៃសាលាក្រុងឡុងប៊ិច បានចេញ បទបញ្ជាសុខាភិបាល ដែលបានធ្វើបច្ចុប្បន្នភាពរួច ដោយចូលជាធរមានភ្លាមៗ ដែលអនុញ្ញាតឱ្យមាន សេវាសាសនា និងពិធីបុណ្យវប្បធម៌ មានមនុស្សចូលរួមនៅក្នុងអគារ ប្រារព្ធឡើងវិញ ដោយមានការដាក់កំហិត ដើម្បីសម្របទៅតាមបម្រែបម្រួល នាពេលថ្មីៗ នេះ លើផែនការសម្រាប់កម្រិតពណ៌ស្វាយ នៃសេដ្ឋកិច្ចកាន់តែមានសុវត្ថិភាព ដែលបានចេញដោយ ហ្គាវីន ញូវសម (Gavin Newsom) ជាអភិបាលកាលីហ្វ័រញ៉ា ។

សេចក្តីសង្ខេប អំពីបទបញ្ជាសុខាភិបាល ដែលបានកែសម្រួលឡើងវិញរួមមាន ៖

**សេវាសាសនា និងពិធីបុណ្យវប្បធម៌ ៖**

- ទីកន្លែងគោរពបូជាដូចជា វិហារគ្រីស្ត វិហារឥស្លាម វិហារជ្វីហ្វ និងវត្ត ព្រមទាំងបុណ្យវប្បធម៌នានាដូចជាពិធីអាពាហ៍ពិពាហ៍ និងពិធីបុណ្យសពអាចប្រតិបត្តិសេវាដោយផ្ទាល់ក្នុងអគារ ឡើងវិញបាន ដោយដាក់មនុស្ស ត្រឹមតែ 25 ភាគរយ នៃបរិមាណអតិបរមារបស់អគារតែប៉ុណ្ណោះ ។
- ការច្រៀង ការសូត្រធម៌ ព្រមទាំង ប្រតិបត្តិ និងការអនុវត្តផ្សេងៗ ទៀត ត្រូវបានហាមឃាត់ សម្រាប់ការជួបជុំ នៅក្នុងអគារ ដោយសារតែមានកំណើនឆ្លង COVID-19 ជាសារវ័ន្ត នៅក្នុងសកម្មភាពទាំងនេះ ។ សកម្មភាពទាំងនេះ មិនត្រូវបានលើកទឹកចិត្តទាល់តែសោះ នៅពេលជួបជុំគ្នានៅក្រៅអគារ ។
- សេវាចំណីអាហារ និង/ឬ ភេសជ្ជៈ អាហារទទួលទៀនក្នុងឆ្នាំងរួមគ្នា និងការទទួលទានលក្ខណៈគ្រួសារ ព្រមទាំងព្រឹត្តិការណ៍ទទួលទានគ្រឿងស្រវឹង នៅតែមានការហាមឃាត់ដដែល ។

ភោជនីយដ្ឋាន និងសណ្ឋាគារ ដែលទទួលរៀបចំពិធីអាពាហ៍ពិពាហ៍ និងពិធីបុណ្យសព នៅតែត្រូវបានតម្រូវឱ្យរៀបចំពិធី តែនៅក្រៅអគារ ដដែល អនុលោមតាមគោលការណ៍ណែនាំ របស់រដ្ឋ ។

ខណៈដែលសេវាផ្ទាល់ នៅក្នុងអគារ អាចប្រារព្ធធ្វើឡើងវិញបាន ជាការសំខាន់ ដែលត្រូវចាត់គ្រប់វិធានការទាំងអស់ ដែលអាចធ្វើទៅ ដើម្បីដាក់កម្រិតនៃការឆ្លងរាលដាល COVID-19 ឱ្យ

នៅតិចបំផុត ហើយធានាឱ្យមានសុវត្ថិភាព សម្រាប់អ្នកគ្រប់គ្នា នៅក្នុងសហគមន៍ ។ អ្នកដែលចូលរួម ក្នុងសកម្មភាពក្នុងអគារ ដូចមានរាយបញ្ជាក់រួចខាងលើនេះ គួរមានការប្រយ័ត្នប្រយែង ក្នុងការរក្សាគម្លាតរាងកាយ ឱ្យបានឆ្ងាយពីគ្នាបំផុត តាមដែលអាចធ្វើទៅបាន, ពាក់ម៉ាស់គ្រប់ពេលចេញទៅទីសាធារណៈ និងលាងសម្អាតដៃ ឱ្យបានញឹកញាប់ ហើយសម្អាតមេរោគ លើផ្ទៃដែលមានគេប៉ះច្រើន ។

រដ្ឋកាលីហ្វ័រញ៉ា បានចេញគោលការណ៍ណែនាំស្តីទី សម្រាប់សេវាសាសនា និងពិធីបុណ្យវប្បធម៌ ដើម្បីសម្របទៅតាមបម្រែបម្រួលនានា ចំពោះផែនការសេដ្ឋកិច្ចកាន់តែមានសុវត្ថិភាព និងជាកិច្ចឆ្លើយតបទៅនឹង សេចក្តីសម្រេច របស់តុលាការកំពូលសហរដ្ឋអាមេរិក ។

បទបញ្ជាសុខភាព ដែលបានធ្វើបច្ចុប្បន្នភាពរួច ក៏ត្រូវបានកែសម្រួលផងដែរ ដើម្បីដើរស្របទៅតាមគោលការណ៍ណែនាំ របស់រដ្ឋកាលីហ្វ័រញ៉ា សម្រាប់សេចក្តីណែនាំ អំពីការបើកថ្នាក់រៀនឡើងវិញ សម្រាប់សិស្សថ្នាក់ទី K-12 ។ សាលារៀន នៅក្នុងទីក្រុងឡុងប៊ិច អាចបើកថ្នាក់ K-6 បង្រៀនដោយផ្ទាល់ឡើងវិញបាន នៅពេលខោនធីឡូស អែនជីឡេសឈានទៅបំពេញបានលក្ខខណ្ឌតម្រូវ មួយចំនួន នៅក្នុងលំដាប់ស្រទាប់ពណ៌ស្វាយ (អត្រាករណី តិចជាង 25 ករណី ក្នុងចំណោមប្រជាពលរដ្ឋ 100,000 នាក់ ក្នុងរយៈពេលយ៉ាងហោចណាស់ 5 ថ្ងៃ) ។

ទីក្រុងឡុងប៊ិច ស្ថិតនៅក្នុងលំដាប់ស្រទាប់ពណ៌ស្វាយ ហើយស្ថិតក្រោមការដាក់កំហិត ខ្លាំងបំផុត, ដែលជាលំដាប់ស្រទាប់ របស់ផែនការរដ្ឋ សម្រាប់សេដ្ឋកិច្ចកាន់តែមានសុវត្ថិភាព, ហេតុនេះ ត្រូវនៅមានការដាក់កំហិតមួយចំនួន ដើម្បីជួយកាត់បន្ថយ ការឆ្លង COVID-19 ជាបន្តទៀត ។ ប្រព័ន្ធ លំដាប់ស្រទាប់ពណ៌ អនុញ្ញាតឱ្យមាន ការបើកដំណើរការឡើងវិញ ដោយផ្អែកលើចំនួនករណី ក្នុងចំណោមប្រជាពលរដ្ឋ 100,000 នាក់ និងអត្រាករណីវិជ្ជមាន ក្នុងចំណោមប្រជាពលរដ្ឋ ដែលបានមកធ្វើតេស្ត COVID-19 ។

បទបញ្ជាសុខភាពដែលត្រូវបានធ្វើឱ្យទាន់សម័យត្រូវបានដាក់ដោយមន្ត្រីសុខាភិបាលទីក្រុងគឺវេជ្ជបណ្ឌិតអានីសាដាវីស និងអនុលោមតាមអំណាចបន្ទាន់ដែលផ្តល់ទៅឱ្យអ្នកគ្រប់គ្រងក្រុងតាមរយៈការប្រកាសអាសន្នក្នុងតំបន់។ វាចូលជាធរមាន ភ្លាមៗ ចាប់ពីថ្ងៃពុធ ទី 10 ខែកុម្ភៈ នេះតទៅ រហូតទាល់តែត្រូវពន្យារពេល, លុបចោល ឬកែសម្រួលជាលាយល័ក្ខណ៍អក្សរ ដោយមន្ត្រីសុខាភិបាល ។

សម្រាប់ព័ត៌មានចុងក្រោយបំផុត អំពី COVID-19 ដែលមានសេចក្តីលំអិត អំពីសកម្មភាពទាំងអស់ របស់សាលាក្រុងឡុងប៊ិច ក្នុងការរក្សាសុវត្ថិភាព របស់ប្រជាពលរដ្ឋរបស់យើង សូមចូលទៅ long-beach.gov/COVID19 ហើយតាម @LongBeachCity នៅលើ Facebook, Twitter និង Instagram ។

# # #